ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣❋៤

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ៦៧៨ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០០៥

# ប្រកាស
# ស្តីពី
# នីតិវិធីអនុវត្តរបបបន្ទុកគោលនយោបាយ
# ចំពោះជនពលី ជនមរណៈ ជនពិការ និងយុទ្ធជន ជនបាត់បង់
# សមត្ថភាពការងារ និងគ្រួសារ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ ០៧/ នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញសេចក្តីសំរេចលេខ ២០ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយចំពោះជនពលី ពិការ និងលិខិតលេខ ៥១៥ សជណ អវ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩១ របស់រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី៖ ...

- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យលេខ៣២ អនក្រ បក ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិសោធនកម្មមាត្រា ៤ ១៤
- និង ១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ បក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គួស្លាប់ បាត់ខ្លួន និងពិការ និងអនុក្រឹត្យលេខ០២ អនក្រ បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ ស្តីពីការកែតម្រូវឡើងវិញ មាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យលេខ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសារាចរអន្តរក្រសួងលេខ ០៤ សកអ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៤ របស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ក្រសួងសុខាភិបាល ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ស្តីពីរបៀបបំពេញសំណុំលិខិត និងសំរេចទទួលស្គាល់ជនពលីពិការ
- បានឃើញសារាចរអន្តរក្រសួងលេខ០០២/៩៧ សរចអ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៧ របស់ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ស្តីពីការណែនាំអនុវត្តន៍ របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងសារាចរអន្តរក្រសួង លេខ ០១/២០០១ សរចអ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ របស់ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ស្តីពីវិសោធនកម្មលើចំណុច ៤ ក្នុង (I) ចំណុច (III) និងចំណុចលេខ ៥ ក្នុង-(IV) នៃសារាចរអន្តរក្រសួង លេខ០០២/៩៧ សរចអ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីការណែនាំអនុវត្តន៍ របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញសារាចរណែនាំអន្តរក្រសួងលេខ ០២ សរណ អក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៥ របស់ក្រសួងការពារជាតិ ក្រសួងសេដកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការអនុវត្តន៍ អនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកាឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្គួស្លាប់ បាត់ខ្លួន និងពិការ និងអនុក្រឹត្យលេខ ០២ អនក្រ បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ ស្តីពីការកែតម្រូវឡើងវិញ មាត្រា៣ មាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យលេខ៤៦ អនក្រ បក ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**ប្រការ១:** ប្រកាសនេះមានគោលបំណង កំណត់នូវបែបបទនិងនីតិវិធី នៃការអនុវត្តរបបឧបត្ថម្ភគោលនយោបាយ ចំពោះគ្រួសារ

ជនពលី-ជនមរណៈ ជនពិការ និងគ្រួសារ ជាអតីតយោធិននៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជននិងប្រជាជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ និងចំពោះនិវត្តជន ជនបាត់បង់សមត្ថភាពការងារ ជាអតីតយោធិន នៃកងយោធពលខេមរភូមិន្ទ។

**ប្រការ២**: ប្រកាសនេះកំណត់ នីតិវិធីអនុវត្តជាក់ស្តែង នូវច្បាប់ អនុក្រឹត្យ សារាចរ សេចក្តីណែនាំ សេចក្តីជូនដំណឹង ស្តីពីគោលរបបឧបត្ថម្ភចំពោះគ្រួសារជនពលី-ជនមរណៈ ជនពិការនិងគ្រួសារ និងបានរៀបចំបញ្ចូលបន្ថែម នូវគោលការណ៍ បែបបទ និងនីតិវិធី នៃការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ។

## ជំពូកទី ២

## ប្រាក់ឧបត្ថម្ភប្រចាំខែរបស់គ្រួសារជនពលី-ជនមរណៈ

**ប្រការ៣**: គ្រួសារជនពលី ត្រូវបានទទួលប្រាក់ឧបត្ថម្ភ តាមកំណត់ដូចតទៅ:

| | |
|---|---|
| ក-កូនបង្កើតក្នុងម្នាក់១ | ៤.០០០ រៀល |
| ខ-ប្រពន្ធ ឬប្តីស្របច្បាប់ | ៣.២០០ រៀល |
| គ-ឪពុកបង្កើត | ៣.២០០ រៀល |
| ឃ-ម្តាយបង្កើត | ៣.២០០ រៀល |

**ប្រការ៤**: កូនជនមរណៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ក្នុងម្នាក់១ ៤.០០០រៀល។

## ជំពូកទី ៣

## ប្រាក់ជូនដំណឹងពលី មរណៈ និងប្រាក់ឧបត្ថម្ភមួយលើកជូនគ្រួសារ

**ប្រការ៥**: គ្រួសារសពនគរបាល មន្ត្រីរាជការស៊ីវិល ពលី ឧបត្ថម្ភជាប្រាក់ចំនួន១៥ខែ នៃប្រាក់បៀវត្សសរុបប្រចាំខែ (ប្រាក់ជូនដំណឹងពលីចំនួន ៣ខែ និងប្រាក់ឧបត្ថម្ភមួយលើកចំនួន១២ ខែ) ដោយផ្អែកតាម លិខិតបញ្ជាក់ប្រាក់បៀវត្ស ឬប្រាក់ឧបត្ថម្ភផ្សេងៗ របស់ក្រសួងស្ថាប័នដើម ។

**ប្រការ៦**: គ្រួសារសព កងសេនាជន និងប្រជាជន ពលី ឧបត្ថម្ភជាប្រាក់ចំនួន ១៥ខែ នៃប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលទោ (ប្រាក់ជូនដំណឹងពលី ចំនួន៣ខែ និង ប្រាក់ឧបត្ថម្ភមួយលើកចំនួន ១២ខែ)។

ប្រាក់បៀវត្សសរុបផ្ទាល់ខ្លួន របស់យុទ្ធជនមានឋានន្តរសក្តិពលទោ សំរាប់ឧបត្ថម្ភជនពលី ឬជនមរណៈ ជាកងសេនាជន និងប្រជាជន ឬជូនគ្រួសារ រួមមាន: ប្រាក់បៀវត្សឋានន្តរសក្តិ ប្រាក់ម្ហូប ប្រាក់តំបន់ (បើមាន) និងប្រាក់បន្ថែមភាគរយ។

## ជំពូកទី ៤

## ប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះជនពិការ និងគ្រួសារ

**ប្រការ៧៖**អត្ថន័យអក្សរប្រើប្រាស់ក្នុងរូបមន្ត ដើម្បីគិតប្រាក់ឧបត្ថម្ភជូនជនពិការ មានដូចតទៅ:

-បស =ប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិន ឬ នគរបាលពិការ ( ក្របខ័ណ្ឌរដ្ឋក្នុងកងកម្លាំងប្រដាប់អាវុធ) រួមមាន:

-ប្រាក់បៀវត្សឋានន្តរសក្តិ

-ប្រាក់ម្ហូប

-ប្រាក់តំបន់ (បើមាន)

-ប្រាក់ប្រពន្ធ ឬ ប្តី (ប្រ)

-ប្រាក់កូន (ក )

-ចំពោះប្រាក់បៀវត្សសរុបចុងក្រោយ (បស) របស់ជនពិការ ជាក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រួមមាន:

-ប្រាក់បៀវត្សមូលដ្ឋាន ឬប្រាក់បៀវត្សសុខុសាធ

-ប្រាក់តំបន់ (បើមាន)

-ប្រាក់កូន (ក)

-ប្រាក់ប្រពន្ធឬ ប្តី (ប្រ)

-និងប្រាក់ឧបត្ថម្ភផ្សេងៗ (បើមាន)

-បផ =ប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនចុងក្រោយ រួមមាន:

-ប្រាក់បៀវត្សឋានន្តរសក្តិ

-ប្រាក់ម្ហូប

-ប្រាក់តំបន់ (បើមាន)

-ប%=ប្រាក់បន្ថែមភាគរយ គិតលើប្រាក់បៀវត្សមូលដ្ឋាន ឬលើប្រាក់បៀវត្សសុខុសាធ ឬលើប្រាក់បៀវត្សឋានន្តរសក្តិសុខុសាធ ។ ប្រាក់នេះត្រូវបានឧបត្ថម្ភ ដោយផ្អែកតាមការកំណត់ របស់រាជរដ្ឋាភិបាល ហើយមានការណែនាំដោយឡែក ។

-កំ=កំរិតភាគរយ នៃប្រាក់ឧបត្ថម្ភជនពិការតាមកំរិតថ្នាក់ពិការ ដែលមានកំណត់ដូចតទៅ:

ចំពោះ កំ ប្រភេទ (ក) គិតលើប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ សំរាប់ជនពិការ ជាក្របខ័ណ្ឌមន្ត្រីរាជការនិងលើប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលទោ សំរាប់ជនពិការក្រៅក្របខ័ណ្ឌមន្ត្រីរាជការ មានកំណត់ដូចតទៅ:

-ថ្នាក់ ទី ១ កំ = ១០០

-ថ្នាក់ ទី ២ កំ = ៨០

-ថ្នាក់ ទី ៣ កំ = ៦០

-ថ្នាក់ ទី ៤ កំ = ៤០

ចំពោះ កំ ប្រភេទ (ខ) គិតលើប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនចុងក្រោយ សំរាប់ជនពិការជាអតីតយោធិននៃកងយោធពលខេមរភូមិន្ទ មានកំណត់ដូចតទៅ:

- ថ្នាក់ទី១ កំ =៩០
- ថ្នាក់ទី២ កំ =៨០
- ថ្នាក់ទី៣ កំ = ៧០

-ជំ=ប្រាក់ជំនួយមុខរបួស

-ប៎១=ប្រាក់ឧបត្ថម្ភអ្នកបំរើជនពិការប្រភេទ (ក) ថ្នាក់ទី ១ ។

-សបឧ =សរុបប្រាក់ឧបត្ថម្ភប្រចាំខែ

**ប្រការ៨:** របៀបគណនាប្រាក់ឧបត្ថម្ភ ជនពិការប្រភេទ (ក) ជាក្របខ័ណ្ឌមន្ត្រីរាជការ មានដូចតទៅ :

ក-ការគិតប្រាក់ជំនួយមុខរបួស(ជំ) ត្រូវយកប្រាក់បៀវត្សសរុបចុងក្រោយ (បស) គុណនឹងកំរិតភាគរយ នៃប្រាក់ឧបត្ថម្ភជនពិការតាមកំរិតថ្នាក់ពិការ (កំ) ចែកនឹង១០០ មានរូបមន្តដូចតទៅ:

$$ជំ = \frac{បស \times កំ}{១០០}$$

ខ-ការសរុបប្រាក់ឧបត្ថម្ភប្រចាំខែ (សបឧ) ត្រូវយកប្រាក់បៀវត្សសរុបចុងក្រោយ (បស) បូកជាមួយប្រាក់បន្ថែមភាគរយ (ប%) បូកជាមួយប្រាក់ជំនួយមុខរបួស (ជំ) និងបើជនពិការថ្នាក់ទី១ ត្រូវបូកជាមួយប្រាក់ឧបត្ថម្ភអ្នកបំរើ (ប៎១) ដែលមានរូបមន្តដូចតទៅ:

ជនពិការថ្នាក់ទី ១ = សបឧ = បស + ប% + ជំ + ប៎១

ជនពិការថ្នាក់ទី ២ ៣ ៤ = សបឧ = បស + ប% + ជំ

**ប្រការ៩:** របៀបគណនាប្រាក់ឧបត្ថម្ភ ជនពិការប្រភេទ (ខ) គ្រប់ថ្នាក់ ជាអតីតយោធិនមានដូចតទៅ:

ក-ការគិតប្រាក់ជំនួយមុខរបួស (ជំ) ត្រូវយកប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនចុងក្រោយ (បជំ) គុណនឹងកំរិតភាគរយនៃប្រាក់ឧបត្ថម្ភជនពិការ តាមកំរិតថ្នាក់ពិការ (កំ) ចែកនឹង ១០០ មានរូបមន្តដូចតទៅ : $ជំ = \frac{បជំ \times កំ}{១០០}$

ខ-ការសរុបប្រាក់ឧបត្ថម្ភប្រចាំខែ (សបឧ) ត្រូវយកប្រាក់បន្ថែមភាគរយ (ប%) បូកជាមួយប្រាក់ជំនួយមុខរបួស (ជំ) បូកជាមួយប្រាក់កូន(ក) និងបូកជាមួយប្រាក់ប្រពន្ធឬប្តី (ប្រ) មានរូបមន្ត ដូចតទៅ: សបឧ = ជំ + ប% + ក + ប្រ

**ប្រការ១០:** ជនពិការប្រភេទ (ខ) ជាអតីតយោធិន ត្រូវបានកែសំរួលប្រាក់ឧបត្ថម្ភ តាមការកំណត់របស់ប្រកាសនេះ ។

មូលដ្ឋានប្រាក់បៀវត្សឋានន្តរសក្តិ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដើម្បីគិតប្រាក់ឧបត្ថម្ភ ត្រូវអនុវត្តតាម សេចក្តីណែនាំលេខ ០៤/៩២ សណន ចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ១៩៩២ របស់ក្រសួងការពារប្រទេស ស្តីពីការអនុវត្តន៏ អនុក្រឹត្យលេខ២៣ អនក្រ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការសំរួលបៀវត្ស របស់កងទ័ពប្រជាជនកម្ពុជា។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវលើកជាសំណើកែសម្រួល សុំសេចក្តីសំរេចពី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ១១:** ជនពិការប្រភេទ (ខ) ជាកងកម្លាំងនគរបាលជាតិ ដែលក្រសួងមហាផ្ទៃ បានបញ្ចេញពីក្របខ័ណ្ឌ នគរបាលជាតិ ផ្ទេរជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយត្រូវបានក្រុមប្រឹក្សាវាយតម្លៃ ប្រភេទថ្នាក់ពិការ

ធ្វើការវាយតម្លៃ មានកំរិតបាត់បង់សមត្ថភាពការងារ លើសពី ២០ភាគរយ ទៅដល់ ១០០ ភាគរយ ត្រូវបានគិតប្រាក់ឧបត្ថម្ភជូនជារៀងរាល់ខែ ស្មើនឹង៦៥ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន។ ចំពោះ កូនប្រពន្ធឬប្តី ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ដូចពេលកំពុងធ្វើការរដ្ឋដែរ មានរូបមន្ត អនុវត្តដូចតទៅ:

$$\text{សបឧ} = \frac{(\text{បផ} \times \text{៦៥})}{\text{១០០}} + \text{ប\%} + \text{ក} + \text{ប្រ}$$

**ប្រការ១២:** ការគិតប្រាក់ឧបត្ថម្ភជនពិការប្រភេទ(ក) គ្រប់ថ្នាក់ក្រៅក្របខ័ណ្ឌមន្ត្រីរាជការ (កងសេនាជនប្រជាជន) មានដូចតទៅ :

ក-ការគិតប្រាក់ជំនួយមុខរបួស(ជំ) ត្រូវយកប្រាក់បៀវត្សសរុបផ្ទាល់ខ្លួន របស់យុទ្ធជនមានឋានន្តរសក្តិពលទោ(បផ) គុណនឹងកំរិតភាគរយនៃប្រាក់ឧបត្ថម្ភជនពិការ តាមកំរិតថ្នាក់ពិការ(កំ) ចែកនឹង១០០មានរូបមន្ត : $\text{ជំ} = \frac{\text{បផ} \times \text{កំ}}{\text{១០០}}$

ខ-ការសរុបប្រាក់ឧបត្ថម្ភប្រចាំខែ(សបឧ) ត្រូវយកប្រាក់បន្ថែមភាគរយ(ប%) បូកជាមួយប្រាក់ជំនួយមុខរបួស(ជំ) បូកជាមួយប្រាក់កូន (ក) បូកជាមួយប្រាក់ប្រពន្ធឬប្តី (ប្រ) និងចំពោះជនពិការថ្នាក់ទី១ ត្រូវបានបន្ថែមប្រាក់អ្នកបំរើម្នាក់ (បំ) មានរូបមន្តដូចតទៅ:

ជនពិការថ្នាក់ទី១ = ជំ + ប% + បំ១ + ក + ប្រ

ជនពិការថ្នាក់ទី ២ ៣ ៤ = ជំ + ប% + ក + ប្រ

## ជំពូកទី ៥

## ប្រាក់សោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារប្រចាំខែនិងគ្រួសារ

**ប្រការ១៣:** អត្ថន័យនៃអក្សរប្រើប្រាស់ កំណត់ប្រាក់សោធននិវត្តន៍មានដូចតទៅ:

-សន៥០ =ប្រាក់សោធននិវត្តន៍អប្បបរមាប្រចាំខែផ្ទាល់ខ្លួន៥០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិប្រចាំខែ

-សន៥០ប្រ =ប្រាក់សោធននិវត្តន៍អប្បបរមា ៥០ ភាគរយសរុបប្រចាំខែ

-សន៨០ =ប្រាក់សោធននិវត្តន៍អតិបរមាប្រចាំខែផ្ទាល់ខ្លួន៨០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិប្រចាំខែ

-សន៨០ប្រ = ប្រាក់សោធននិវត្តន៍អតិបរមា ៨០ ភាគរយសរុបប្រចាំខែ

-$\text{២}\frac{(\text{៤}^{\text{ឆ-៣}} + \text{៦}^{\text{ឆ-៥}})}{\text{១០០}}$ =រូបមន្តនៃអត្រាប្រាក់បន្ថែម ២ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំទី៤ និងឆ្នាំទី៦ នៃរយៈពេលបំរើការងារយោធា និងស៊ីវិល ដែល (ឆ ) ជាចំនួនឆ្នាំបំរើការងារ ហើយលេខ(៣) និងលេខ(៥) ជាចំនួនដក

-បអន= ប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហានប្រចាំខែ (នាយចំណង់) រួមមាន:

-ប្រាក់បៀវត្សឋានន្តរសក្តិ (ប)

-ប្រាក់ម្ហូប និងអង្ករ (ហ)

-ប្រាក់បន្ថែមភាគរយ (ប%) គិតលើប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ

-ប្រាក់បំណាច់មុខងារ (ម) (បើមាន)

-បអនប្រ=ប្រាក់សោធននិវត្តន៍ អប្បបរិមាប្រចាំខែរបស់នាយទាហាន

-តំ = ប្រាក់តំបន់ (បើមាន)

-អភ១៥ឬ២០=ប្រាក់អាទិភាព១៥ឬ២០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ សំរាប់យោធិនបំរើការងារ មុនឆ្នាំ ១៩៧៩ ឬមុនឆ្នាំ ១៩៧០

-សភ១៥=ប្រាក់បំណាច់ប៉ះពាល់សុខភាព ត្រូវបានអត្រាបន្ថែម១៥ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ

-ប្រ = ប្រាក់ប្រពន្ធ ឬ ប្តី

-ក = ប្រាក់កូន

-(បរ+កព)=ប្រាក់អ្នកបើកបរនិងកងការពារ សំរាប់និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ មានឋានន្តរសក្តិជាឧត្តមសេនីយ ឬវីរជន

-បធ=ប្រាក់បៀវត្សឋានន្តរសក្តិផ្ទាល់ខ្លួន រួមមាន :

- ប្រាក់បៀវត្សឋានន្តរសក្តិ (ប)
- ប្រាក់បន្ថែមភាគរយ (ប%)
- ប្រាក់ម្ហូប និងអង្ករ (ហ)
- ប្រាក់បំណាច់មុខងារ (ម) (បើមាន)

**ប្រការ១៤**:របៀបគណនា ប្រាក់សោធននិវត្តន៍អប្បបរមា ៥០ភាគរយ (សន៥០) មានដូចតទៅ:

១-រូបមន្តប្រាក់សោធននិវត្តន៍ អប្បបរមាប្រចាំខែផ្ទាល់ខ្លួន ៥០ភាគរយ (សន៥០) មានរូបមន្តដូចខាងក្រោម:

$$\text{សន៥០} = \left[ \frac{(\text{បធ} \times \text{៥០})}{\text{១០០}} + \frac{\text{២}\,(\text{៤}^{\text{ន-៣}} + \text{៦}^{\text{ន-៥}})}{\text{១០០}} \right]$$

-ប្រាក់សោធននិវត្តន៍អប្បបរមាផ្ទាល់ខ្លួន ប្រចាំខែ៥០ភាគរយ(សន៥០) មិនត្រូវលើសពី៨០ភាគរយ នៃប្រាក់សោធននិវត្តន៍អតិបរមា ឬក៏មិនត្រូវទាបជាង ប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហាន (នាយចំណង់) ករណីទាបជាងត្រូវដំឡើងអោយស្មើ (បអន)។

២- រូបមន្តប្រាក់សោធននិវត្តន៍អប្បបរមា ៥០ភាគរយសរុបប្រចាំខែ(សន៥០ប្រ) មានដូចតទៅ:

សន៥០ប្រ = សន៥០ + តំ + អភ១៥ឬ២០ + សភ១៥ + ប្រ + ក

ករណីប្រាក់សោធននិវត្តន៍អប្បបរមាផ្ទាល់ខ្លួន ប្រចាំខែ៥០ភាគរយ(សន៥០) មានកំរិតទាប ហើយត្រូវបានគេដំឡើងឱ្យស្មើប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហាន (បអន) ប្រាក់សោធននិវត្តន៍អប្បបរមា ៥០ភាគរយសរុបប្រចាំខែ (សន៥០ប្រ) ត្រូវអនុវត្តតាមរូបមន្តដូច្នេះវិញ:

បអនប្រ= បអន+ តំ + អភ១៥ឬ២០ + សភ១៥ + ប្រ + ក

**ប្រការ១៥**:របៀបគណនា ប្រាក់សោធននិវត្តន៍អតិបរមា៨០ភាគរយ (សន៨០) មានដូចតទៅ:

១-រូបមន្តប្រាក់សោធននិវត្តន៍ អតិបរមាផ្ទាល់ខ្លួនប្រចាំខែ៨០ភាគរយ នៃបៀវត្សឋានន្តរសក្តិប្រចាំខែ មានដូចតទៅ:

$$\text{សន៨០} = \frac{\text{បធ} \times \text{៨០}}{\text{១០០}}$$

ប្រាក់សោធននិវត្តន៍អតិបរមា៨០ ភាគរយផ្ទាល់ខ្លួនប្រចាំខែ (សន៨០) មិនត្រូវទាបជាងប្រាក់បៀវត្សរ៍មាន្តរសក្តិអប្បបរមារបស់នាយទាហានឡើយ បើមានករណីទាបជាងត្រូវដំឡើងអោយស្មើ (បអន)។

២-រូបមន្តប្រាក់សោធននិវត្តន៍អតិបរមាសរុបប្រចាំខែ ៨០ ភាគរយ (សន៨០ប្រ) មានដូចតទៅ:

សន៨០ប្រ = សន៨០ + តំ+ អភ១៥ឬ២០ + សភ១៥ + ប្រ + ក

ករណីប្រាក់សោធននិវត្តន៍អតិបរមា៨០ ភាគរយផ្ទាល់ខ្លួនប្រចាំខែ (សន៨០) មានកំរិតទាប ហើយត្រូវបានគេដំឡើងឱ្យស្មើប្រាក់បៀវត្សរ៍មាន្តរសក្តិអប្បបរមា របស់នាយទាហាន (បអន) ប្រាក់សោធននិវត្តន៍អតិបរមា ៨០ភាគរយ សរុបប្រចាំខែ (សន៨០ប្រ) ត្រូវអនុវត្តតាមរូបមន្តដូច្នេះវិញ:

បអនប្រ = បអន+ តំ + អភ១៥ឬ២០ + សភ១៥ + ប្រ + ក

**ប្រការ១៦:** ប្រាក់សោធននិវត្តន៍អប្បបរមា៥០ភាគរយ (សន៥០) និងប្រាក់សោធននិវត្តន៍អតិបរមា ៨០ភាគរយ (សន៨០) របស់និវត្តជន ដែលមានឋាន្តរសក្តិ ជាឧត្តមសេនីយ ឬជាវីរជន ត្រូវបានបន្ថែមប្រាក់ អ្នកបើកបរនិងកងការពារ ផ្អែកតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល មានរូបមន្តបន្ថែម (+បរ +កព) ។

**ប្រការ១៧:** អត្ថន័យនៃអក្សរប្រើប្រាស់ កំណត់ប្រាក់សោធនបាត់បង់សមត្ថភាពការងារ មានដូចតទៅ:

-សប៥០=ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមាប្រចាំខែផ្ទាល់ខ្លួនស្មើនឹង៥០ភាគរយនៃប្រាក់បៀវត្សរ៍ឋាន្តរសក្តិប្រចាំខែចុងក្រោយ ។

-សប៥០ប្រ = ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមា សរុបប្រចាំខែស្មើនឹង៥០ភាគរយ

-សបចំប្រ = ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ចំណាត់ថ្នាក់សរុបប្រចាំខែ

-$១.៥\left(\frac{៤^{ឆ-៣} + ៦^{ឆ-៥}}{១០០}\right)$ = រូបមន្តអត្រាប្រាក់បន្ថែម១.៥ ភាគរយ គិតលើប្រាក់បៀវត្សរ៍ឋាន្តរសក្តិសុទ្ធសាធក្នុង ១ឆ្នាំ ចាប់ពីឆ្នាំទី៤ និងឆ្នាំទី ៦ នៃរយៈពេលបំរើការងារក្នុងយោធានិងស៊ីវិល ដែល (ឆ) ជាចំនួនឆ្នាំបំរើការហើយលេខ(៣) និងលេខ(៥) ជាចំនួនដក ។

-អវី១០=ប្រាក់អត្រាបន្ថែម ១០ភាគរយ គិតលើប្រាក់បៀវត្សរ៍ឋាន្តរសក្តិសុទ្ធសាធ សំរាប់ជនបាត់បង់សមត្ថភាពការងារមានងារជាវីរជន ។

-បំ១=ប្រាក់ឧបត្ថម្ភប្រចាំខែសំរាប់អ្នកជំនួយកិច្ចការ របស់ជនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ ត្រូវបានឧបត្ថម្ភស្មើ នឹងប្រាក់បៀវត្សរ៍ឋាន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលទោ។

-កំ=កំរិតភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់ គិតលើប្រាក់បៀវត្សរ៍ឋាន្តរសក្តិផ្ទាល់ខ្លួនដែលមានកំណត់ដូចតទៅ%

- ថ្នាក់ទី១ កំ = ១០០
- ថ្នាក់ទី២ កំ = ៨០
- ថ្នាក់ទី៣ កំ = ៦០

-ចំពោះ បអន សភ១៥ បជ ក ប្រ មានអត្ថន័យដូចមានកំណត់ក្នុងប្រការ ១៣ ជំពូកទី ៥

-បអន៥០=ប្រាក់សោធនបាត់បង់សមត្ថភាពការងារ អប្បបរមា៥០ភាគរយ របស់នាយទាហាន(នាយចំណង់)

-បអន៥០ប្រ= ប្រាក់សោធនបាត់បង់សមត្ថភាពការងារ អប្បបរមាសរុបប្រចាំខែ៥០ភាគរយ របស់នាយទាហាន

**ប្រការ១៨:** របៀបគណនា ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ៥០ភាគរយ(សប៥០) មានដូចតទៅ៖

១-រូបមន្តប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន ៥០ភាគរយ

$$\text{សប៥០} = \left[ \frac{(\text{បផ} \times \text{៥០})}{\text{១០០}} + \frac{\text{១,៥}(\text{៤}^{\text{ន-៣}} + \text{៦}^{\text{ន-៥}})}{\text{១០០}} \right]$$

ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ផ្ទាល់ខ្លួន៥០ភាគរយនេះ (សប៥០) សរុបមិនឱ្យលើសពី៦០ភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ ឬមិនឱ្យទាបជាង៥០ភាគរយ នៃប្រាក់បៀវត្សគោលនៃរង្វាន់ថ្នាក់ បូករមាម៉ាទីម៉ឺនអប្បបរមា របស់នាយទាហានឡើយ ករណីទាបជាងត្រូវដំឡើងឱ្យស្មើ តាមមានរូបមន្ត បអន៥០= $\frac{\text{បអន} \times \text{៥០}}{\text{១០០}}$

២-រូបមន្តប្រាក់សោធនបាត់បង់សមត្ថភាពការងារ ៥០ភាគរយ សរុបប្រចាំខែមាន:

$$\text{សប៥០ប្រ} = \text{សប៥០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬករណីប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន ៥០ ភាគរយនេះ (សប៥០) មានកំរិតទាប ហើយត្រូវបានគេដំឡើងឱ្យស្មើ៥០ភាគរយ នៃប្រាក់បៀវត្សគោលនៃរង្វាន់ថ្នាក់ អប្បបរមា របស់នាយទាហាន ប្រាក់សោធនបាត់បង់សមត្ថការងារ ៥០ភាគរយសរុបប្រចាំខែ ត្រូវបានអនុវត្តតាមរូបមន្តដូចតទៅ :

$$\text{បអន៥០ប្រ} = \text{បអន៥០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

**ប្រការ១៩:** របៀបគណនាប្រាក់សោធនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់

ការគណនាប្រាក់សោធនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់ ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោមនេះ:

$$\text{- ថ្នាក់ទី១} = \text{សបចំប្រ} = \frac{(\text{បផ} \times \text{កំ})}{\text{១០០}} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក} + \text{បំ១}$$

$$\text{- ថ្នាក់ទី ២, ៣} = \text{សបចំប្រ} = \frac{(\text{បផ} \times \text{កំ})}{\text{១០០}} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

**ប្រការ២០:** ចំពោះជនបាត់បង់សមត្ថភាពការងារ មានងារជាវីរជន ត្រូវទទួលបានអត្រាប្រាក់បន្ថែម ១០ ភាគរយនៃប្រាក់បៀវត្សគោលនៃរង្វាន់ថ្នាក់សុទ្ធសាធមានរូបមន្ត(+អវី១០) ។

## ជំពូកទី ៦

## ការកែតម្រូវប្រាក់ឧបត្ថម្ភខុសសញ្ញា

**ប្រការ២១:** ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ ប្រាក់ឧបត្ថម្ភគ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ គ្រប់ប្រភេទ គ្រប់ថ្នាក់ និងគ្រួសារ ។ ក្នុងករណីមានការខុសឆ្គង ត្រូវកែសំរួលឱ្យបានសមស្រប និងត្រឹមត្រូវតាមគោលរបបកំណត់ ។ បើមានករណីប្តឹងតវ៉ា អំពីការគិតប្រាក់គោលនយោបាយខុស លើសឬខ្វះ កាត់បន្ថយ ឬសងវិញ ត្រូវគិតចាប់ពីថ្ងៃ ខែ ឆ្នាំដែលបានគិតខុសនោះ ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើសំណើសុំសេចក្តីសំរេច កែសម្រួលរបបឧបត្ថម្ភគោលនយោបាយដែលបានគិតខុសនោះ ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្ត ។

## ជំពូកទី ៧

## ប្រាក់ឧបត្ថម្ភចំពោះជនពលី ជនមរណៈ ដោយរបួសស៊េរី ដោយជំងឺ ឬគ្រោះថ្នាក់ធម្មតា

**ប្រការ២២:** ជនពិការប្រភេទ(ក)និង(ខ) និវត្តជន ជនបាត់បង់សមត្ថភាពការងារគ្រប់ថ្នាក់ បានមរណៈដោយរបួសស៊េរី ឬ ដោយជំងឺឬគ្រោះថ្នាក់ធម្មតា ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភជូន តាមស្ថានភាពជំងឺ ឬតាមស្ថានភាពគ្រោះថ្នាក់ ។

**ប្រការ២៣:** ប្រាក់បូជា ឬបញ្ចុះសពជនពលីជាអតីតយោធិនពិការ បានពលីដោយរបួសស៊េរី ឧបត្ថម្ភជាប្រាក់ចំនួន៩ខែ នៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ របស់អតីតសាមីជនពិការ ។

**ប្រការ២៤:** ប្រាក់បូជាឬបញ្ចុះសពជនពលី ជាអតីតនគរបាលមន្ត្រីរាជការស៊ីវិលពិការ បានពលីដោយរបួសស៊េរី ឧបត្ថម្ភជាប្រាក់ចំនួន៣ខែនៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់សាមីជនពិការ ។

**ប្រការ២៥:** ប្រាក់បូជា ឬបញ្ចុះសពជនពលី ជាអតីតកងសេនាជន ប្រជាជន ពិការ បានពលីដោយរបួសស៊េរី ឧបត្ថម្ភជាប្រាក់ចំនួន៣ខែនៃប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលទោ ។

**ប្រការ២៦:** គ្រួសារសពយោធិនពលី ឧបត្ថម្ភជាប្រាក់មួយលើកចំនួន១៥ខែ នៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ របស់អតីតសាមីជនពិការ ។

**ប្រការ២៧:** គ្រួសារសពជនពលី ជានគរបាល មន្ត្រីរាជការស៊ីវិល ពលី ឧបត្ថម្ភជាប្រាក់មួយលើកចំនួន១៥ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់សាមីជនពិការ( ប្រាក់ជូនដំណឹងពលីចំនួន៣ខែ និងប្រាក់ឧបត្ថម្ភមួយលើកចំនួន១២ខែ) ។

**ប្រការ២៨:** គ្រួសារសពជនមរណៈ ជានគរបាល មន្ត្រីរាជការស៊ីវិល កងសេនាជន និងប្រជាជន ឧបត្ថម្ភជាប្រាក់មួយលើកចំនួន៦ខែ នៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ របស់សាមីជនពិការ ។

**ប្រការ២៩:** និវត្តជន និងជនបាត់បង់សមត្ថភាពការងារ បានមរណភាពដោយជំងឺ ឬប្រការផ្សេងៗ ត្រូវបានទទួលប្រាក់ធានារ៉ាប់រងសំរាប់គ្រួសារតែម្តងគត់ ស្មើនឹងប្រាក់បៀវត្ស និងប្រាក់បំណាច់របស់សាមីជន គុណនឹងចំនួន១២ខែ ។

**ប្រការ៣០:** គ្រួសារជនពលី ត្រូវបានទទួលប្រាក់ឧបត្ថមជារៀងរាល់ខែ ដូចមានចែងក្នុងចំណុច ក ខ គ ឃ នៃប្រការ៣ ជំពូកទី២ ឯគ្រួសារជនមរណៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ដូចមានចែងក្នុងប្រការ៤ ជំពូកទី ២ ។

**ប្រការ៣១:** ការបំពេញបែបបទ និងសំរេចទទួលស្គាល់ជាជនពលី ជនមរណៈ និងផ្តល់ប្រាក់ឧបត្ថម្ភជូន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវបំពេញតាមនីតិវិធី និងបែបបទ ដូចតទៅ :

ក-ត្រូវមានលិខិតបញ្ជាក់ជាជនពលី ឬជាជនមរណៈ ពីអាជ្ញាធរឃុំសង្កាត់ ស្រុកខ័ណ្ឌ ឬពីមន្ទីរពេទ្យរដ្ឋ ផ្នែកស៊ីវិល ឬយោធា ឬនគរបាល ។

ខ-ធ្វើលិខិតស្នើសុំលុបឈ្មោះជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ពីបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ ដោយបញ្ជាក់កាលបរិច្ឆេទលុប ឱ្យបានច្បាស់លាស់មានបញ្ជីរាយនាម និងតារាងបញ្ជាក់ប្រាក់ឧបត្ថម្ភភ្ជាប់ ។

គ-ធ្វើលិខិតស្នើសុំប្រាក់ ឧបត្ថម្ភជូនជនពលី ជនមរណៈ និងគ្រួសារ ដោយមានបញ្ជីរាយនាមភ្ជាប់ ។

ឃ-ត្រូវភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម :

- លិខិតទទួលស្គាល់ជា ជនពលី ឬ ជនមរណៈ ២ ច្បាប់
- ប្រវត្តិរូបសង្ខេប ២ ច្បាប់
- តារាងបញ្ជាក់ប្រាក់ឧបត្ថម្ភប្រចាំខែ ២ ច្បាប់

**ប្រការ៣២:**សិទ្ធិសំរេចលុបឈ្មោះជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារនិងទទួលស្គាល់ ជាជនពលីឬជនមរណៈ និងផ្តល់របបឧបត្ថម្ភជូន ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**ប្រការ៣៣:**គ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ មានសិទ្ធិទទួលប្រាក់ឧបត្ថម្ភប្រចាំខែមានរយៈពេល៣ខែ បន្ទាប់ពីថ្ងៃខែឆ្នាំ អស់សុពលភាពទទួលរបបឧបត្ថម្ភ ត្រូវបានលុបឈ្មោះចេញពីបញ្ជីបើកប្រាក់ ។

## ជំពូកទី ៤
## ការគ្រប់គ្រងគ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន
## ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ

**ប្រការ៣៤:**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ គ្រួសារជនពលី -ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ដែលមានឈ្មោះក្នុងសេចក្តីសំរេច ប្រកាសទទួលស្គាល់កន្លងមក ហើយដែលបាននិងកំពុងទទួល ប្រាក់ឧបត្ថម្ភជារៀងរាល់ខែ នៅតាមបណ្តាការិយាល័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទាស្រុក ខណ្ឌ ក្រោមការគ្រប់គ្រងរបស់ខ្លួន ។

**ប្រការ៣៥:**ការត្រួតពិនិត្យ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ត្រូវអនុវត្តដូចតទៅ :

- វត្តមានពិតប្រាកដរបស់មុខសញ្ញាផ្ទាល់
- វត្តមានពិតប្រាកដរបស់គ្រួសារ( មានឬមិនមានមនុស្សពិតប្រាកដ ដែលត្រូវជា ប្រពន្ធ ប្តីឬកូន )
- កូនមានអាយុពី ១៥ឆ្នាំ ឬ ១៨ឆ្នាំ កំពុងសិក្សា ឬមិនបានសិក្សា ។
- កូនទើបកើតថ្មី
- មុខសញ្ញាទើបតែរៀបអាពាហ៍ពិពាហ៍លើកដំបូង ហើយប្រពន្ធ ឬប្តីនោះ មិនទាន់បានបញ្ចូលឈ្មោះក្នុងបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ។

**ប្រការ៣៦:**ការត្រួតពិនិត្យ គ្រួសារជនពលី -ជនមរណៈ ត្រូវអនុវត្តដូចតទៅ:

- វត្តមានទាំងស្រុង (មានឬមិនមាន ឪពុក ម្តាយកូន ប្រពន្ធ ឬប្តី) នៃគ្រួសារជនពលី -មរណៈ
- ឪពុក ម្តាយបង្កើត បានស្លាប់
- ប្រពន្ធ ឬប្តី មានប្តីឬប្រពន្ធ ថ្មីទៀត
- កូនមានអាយុពី១៥ឆ្នាំ ឬ១៨ឆ្នាំ កំពុងសិក្សាឬមិនបានសិក្សា ។

**ប្រការ៣៧:**ក្រោយពីបានត្រួតពិនិត្យស្រាវជ្រាវឃើញមាន គ្រួសារពលី-មរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ មិនពិតប្រាកដ កូនលើសអាយុមិនសិក្សា ឬផុតសិទ្ធិទទួលប្រាក់ឧបត្ថម្ភ ត្រូវធ្វើសំណើសុំលុបឈ្មោះ ចេញពីបញ្ជី

បើកប្រាក់ឧបត្ថម្ភប្រចាំខែ ។

បែបបទ និងនីតិវិធី នៃការលុបឈ្មោះមានដូចតទៅ :

១- លុបឈ្មោះ កូន និងបន្ទុក

២- លុបឈ្មោះមុខសញ្ញា និងគ្រួសារទាំងស្រុង

ត្រូវមានសំណុំលិខិដូចតទៅ:

១-លិខិតស្នើសុំលុបឈ្មោះ ដោយបញ្ជាក់កាលបរិច្ឆេទលុប ឱ្យបានច្បាស់លាស់

២-បញ្ជីរាយនាមមុខសញ្ញា និង គ្រួសារ ។

**ប្រការ៣៨:** ចំពោះការស្នើសុំបញ្ចូល ប្រាក់ឧបត្ថម្ភកូនមុខសញ្ញាទើបកើតថ្មី ឬមុខសញ្ញាទើបរៀបអាពាហ៍ពិពាហ៍គ្រាដំបូង ត្រូវមានសំណុំលិខិតដូចតទៅ:

១-លិខិតស្នើសុំបញ្ចូលឈ្មោះកូន ឬបន្ទុក ( ប្រពន្ធ ឬប្ដី)

២-បញ្ជីរាយនាមមុខសញ្ញានិងគ្រួសារ

៣-សំបុត្រកំណើត ១សន្លឹក (ច្បាប់ចម្លងសំរាប់កូន) ឬលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ១សន្លឹក (ច្បាប់ចម្លងសំរាប់ប្រពន្ធ ឬប្ដី)

**ប្រការ៣៩:** កូនរបស់មុខសញ្ញា កំពុងទទួលប្រាក់ឧបត្ថម្ភជារៀងរាល់ខែ មានអាយុពី១៥ឆ្នាំ ឬ១៨ឆ្នាំឡើងទៅ កំពុងបន្តការសិក្សា ត្រូវមានលិខិតបញ្ជាក់ពីសាលា ដែលកូននោះកំពុងសិក្សាហើយការប្រមូលយកលិខិតនេះ ត្រូវធ្វើជារៀងរាល់ឆ្នាំនៅត្រីមាសទី៤នៃឆ្នាំដើម្បីរក្សាទុកជាឯកសារ ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើលិខិតជូនដំណឹងឱ្យបានមុន ក្នុងអំឡុងត្រីមាស ទី៣នៃ ឆ្នាំ ផុតត្រីមាសទី៤ កូនដែលគ្មានលិខិតបញ្ជាក់ការសិក្សា ត្រូវលើកជាសំណើសុំលុបឈ្មោះ ចេញពីបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ ចាប់ពីខែមករានៃឆ្នាំបន្ទាប់ ។

## ជំពូកទី ៥

## លក្ខខណ្ឌសម្បត្តិទទួលរបបឧបត្ថម្ភគោលនយោបាយ

## នៃគ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ

**ប្រការ៤០:** មុខសញ្ញា និងគ្រួសារដែលបានផ្ទេរ ពីក្រសួងស្ថាប័ននានា មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីទទួលប្រាក់ឧបត្ថម្ភ ត្រូវមានការពិនិត្យ និងកំណត់ប្រាក់ឧបត្ថម្ភ អោយបានត្រឹមត្រូវ តាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

**ប្រការ៤១:** នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវពិនិត្យបញ្ជីឈ្មោះកូនក្នុងប្រវត្តិរូបសង្ខេប មានអាយុលើសពី១៥ ឬ១៨ឆ្នាំ ហើយបញ្ជាក់ថានៅរៀន ត្រូវស្នើប្រាក់ឧបត្ថម្ភជូន តែបើមិនមានបញ្ជាក់ថារៀនទេ មិនត្រូវស្នើប្រាក់ឧបត្ថម្ភជូនឡើយ ។ ចំពោះកូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ ដែលកើតបាន៣០០ថ្ងៃ ក្រោយពីក្រសួងការពារជាតិ ប្រកាសដាក់ឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថភាពការងារ ពុំទាន់បានទទួលប្រាក់ឧបត្ថម្ភ ត្រូវកំណត់ជូនតាមគោលការណ៍ និង

របបកំណត់ តែតម្រូវឱ្យកូនទាំងនោះ មានសំបុត្របញ្ជាក់កំណើត ពីអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៤២:** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវធ្វើសំណើសុំលុបឈ្មោះកូន ដែលពុំមានលិខិតបញ្ជាក់ការសិក្សា។

**ប្រការ៤៣:** កូន ឬបន្ទុកគ្រួសាររបស់មុខសញ្ញា (លើកលែងឪពុកម្តាយបង្កើតរបស់ជនពលី) ដែលមានឈ្មោះ ក្នុងប្រវត្តិរូបសង្ខេប អាចកំណត់ប្រាក់ឧបត្ថម្ភជូនបាន លុះត្រាតែស្ថានភាព ប្រវត្តិរូបសង្ខេបស្របគ្នា ជាមួយស្ថានភាព នៃលិខិតផ្តល់ហិរញ្ញវត្ថុ ឬលិខិតបញ្ជាក់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែ ។ ករណីផ្ទុយគ្នា កូនឬបន្ទុកទាំងនោះ មិនត្រូវកំណត់ប្រាក់ឧបត្ថម្ភជូនទេ តែបើមានការតវ៉ា ដោយសាមីជននោះ មានសំបុត្រកំណើត ឬលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ឬសាលក្រមតុលាការ ត្រូវកំណត់ប្រាក់ឧបត្ថម្ភជូន តាមច្បាប់និងលិខិតបទដ្ឋានជាធរមាន។

**ប្រការ៤៤:** គ្រួសាររបស់ជនពលី ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ បានពិនិត្យស្រាវជ្រាវឃើញមានតែឈ្មោះ តែពុំមានមនុស្សពិតប្រាកដ ត្រូវលើកសំណើសុំលុបឈ្មោះ ចេញពីបញ្ជីបើកប្រាក់។

## ជំពូកទី ១០

## រូបមន្តគណនាប្រាក់ឧបត្ថម្ភគ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ការដកចេញ និងបន្ថែមចូល

**ប្រការ៤៥:** គ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ដែលផុតសិទ្ធិទទួលប្រាក់ឧបត្ថម្ភ ត្រូវបានគណនាដកប្រាក់ឧបត្ថម្ភចេញ ឯមុខសញ្ញាដែលមានលក្ខណៈសម្បត្តិកំណើនថ្មី ត្រូវបានគណនាប្រាក់ឧបត្ថម្ភបន្ថែមចូល ក្នុងបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ។

**ប្រការ៤៦:** ខ្ទង់ប្រាក់ឧបត្ថម្ភគ្រួសារជនពលី -ជនមរណៈ ត្រូវដកចេញ មានដូចតទៅ:

-កូនជនពលី មរណៈ ក្នុងម្នាក់ៗ ៤០០០រៀល

-ប្រពន្ធឬប្តីជនពលី ៣២០០រៀល

-ឪពុកម្តាយបង្កើតជនពលីក្នុងម្នាក់ៗ ៣២០០រៀល

**ប្រការ៤៧:** ខ្ទង់ប្រាក់ឧបត្ថម្ភជនពិការប្រភេទ ( ក ) ជាអតីតក្របខ័ណ្ឌរដ្ឋ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

- ថ្នាក់ទី១ សបឧ = បស +ប%+ជ +ប៉១
- ថ្នាក់ទី ២,៣,៤ សបឧ = បស +ប%+ជ

**ប្រការ៤៨:** ខ្ទង់ប្រាក់ឧបត្ថម្ភជនពិកាប្រភេទ (ក) ក្រៅក្របខ័ណ្ឌរដ្ឋ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

- ថ្នាក់ទី១ សបឧ = ប%+ជ +ប៉១ +ក +ប្រ
- ថ្នាក់ទី ២,៣,៤ សបឧ = ប%+ជ+ក+ ប្រ

**ប្រការ៤៩:** ខ្ទង់ប្រាក់ឧបត្ថម្ភជនពិការប្រភេទ (ខ) គ្រប់ថ្នាក់ជាអតីតយោធិន ត្រូវដកចេញតាមរូបមន្តដូចតទៅ :

សបឧ = ជ +ប% +ក +ប្រ

ចំពោះជនពិការប្រភេទ (ខ) ជាអតីតនគរបាល ខ្ទង់ប្រាក់ត្រូវដកចេញ តាមរូបមន្តដូចតទៅ:

$$\text{សបឧ} = \frac{(\text{បផ} \times ៦៥)}{១០០} + \text{ប\%} + \text{ក} + \text{ប្រ}$$

**ប្រការ៥០:** ខ្ទង់ប្រាក់របស់និវត្តជន ដែលទទួលរបបសោធននិវត្តន៍អប្បបរមា៥០ភាគរយ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

$$\text{សន៥០ប្រ} = \text{សន៥០} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬ $$\text{បអនប្រ} = \text{បអន} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

**ប្រការ៥១:** ខ្ទង់ប្រាក់ឧបត្ថម្ភរបស់និវត្តជន ដែលទទួលរបបសោធននិវត្តន៍អតិបរមា៨០ភាគរយត្រូវដកចេញ តាមរូបមន្តដូចតទៅ:

$$\text{សន៨០ប្រ} = \text{សន៨០} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬ $$\text{បអនប្រ} = \text{បអន} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

**ប្រការ៥២:** ខ្ទង់ប្រាក់ឧបត្ថម្ភរបស់និវត្តជន មានងារន្តរសក្តិជាឧត្តមសេនីយ ឬជាវីរជន ដែលមានរបបអ្នកបើកបរ និងកងការពារ ខ្ទង់ប្រាក់ត្រូវដកចេញបន្ថែមតាមរូបមន្តរូបមន្តដូចតទៅ: (-បរ + កព) ។

**ប្រការ៥៣:** ខ្ទង់ប្រាក់ឧបត្ថម្ភ របស់ជនបាត់បង់សមត្ថភាពការងារ ៥០ភាគរយ ត្រូវដកចេញ តាមរូបមន្តដូចតទៅ :

$$\text{សប៥០ប្រ} = \text{សប៥០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬ $$\text{បនអ៥០ប្រ} = \text{បអន៥០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

**ប្រការ៥៤:** ខ្ទង់ប្រាក់ឧបត្ថម្ភ របស់ជនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

- ថ្នាក់ទី១ $$= \text{សបចំ} = \frac{(\text{បផ} \times \text{កំ})}{១០០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក} + \text{បំ១}$$
- ថ្នាក់ទី ២, ៣ $$= \text{សបចំ} = \frac{(\text{បផ} \times \text{កំ})}{១០០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

**ប្រការ៥៥:** ខ្ទង់ប្រាក់ឧបត្ថម្ភ របស់ជនបាត់បង់សមត្ថភាពការងារ មានងារជាវីរជន ត្រូវបានកាត់បន្ថែមអត្រា១០ ភាគរយនៃប្រាក់បៀវត្សងារន្តរសក្តិសុទ្ធសាធ តាមរូបមន្តដូចតទៅ: (-អវី១០) ។

**ប្រការ៥៦:** ការដក ឬបញ្ចូលប្រាក់ឧបត្ថម្ភកូន ឬបន្ទុក របស់ជនពិការគ្រប់ប្រភេទគ្រប់ថ្នាក់ ត្រូវអនុវត្តតែក្នុងខ្ទង់ប្រាក់ជំនួយមុខរបួស (ជំ) និងក្នុងខ្ទង់ប្រាក់ឧបត្ថម្ភកូន (ក) ឬបន្ទុក (ប្រ) របស់ជនពិការតែប៉ុណ្ណោះ តាមវិធានដូចខាងក្រោម

ក-កូនជនពិការក្របខ័ណ្ឌរដ្ឋ ត្រូវកាត់ចេញឬបញ្ចូលបន្ថែមតាមរូបមន្ត : $$\frac{(\text{ក} \times \text{កំ})}{១០០} + \text{ក}$$

ខ-ប្រពន្ធ ឬប្តី របស់ជនពិការក្របខ័ណ្ឌរដ្ឋ ត្រូវកាត់ចេញ ឬ បញ្ចូលបន្ថែមតាមរូបមន្ត: $$\frac{(\text{ប្រ} \times \text{កំ})}{១០០} + \text{ប្រ}$$

គ-ចំពោះកូន (ក) និងបន្ទុក (ប្រ) របស់ជនពិការប្រភេទ (ក) ក្រៅក្របខ័ណ្ឌរដ្ឋឬរបស់ជនពិការប្រភេទ (ខ) និងនិវត្តជន ជនបាត់បង់សមត្ថភាពការងារ ការដកប្រាក់ឬបញ្ចូលប្រាក់ ត្រូវគិតតែក្នុងខ្ទង់ ប្រាក់ឧបត្ថម្ភកូន (ក) ឬបន្ទុក (ប្រ) តែប៉ុណ្ណោះ

## ជំពូកទី ១១

## ការផ្ទេរប្រាក់ឧបត្ថម្ភគ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ពីខេត្តក្រុងមួយ ទៅខេត្តក្រុងមួយទៀត

**ប្រការ៥៧:** ការផ្ទេរត្រូវធ្វើឡើង២ដងក្នុង១ឆ្នាំ គឺក្នុងខែមករា និងក្នុងខែកក្កដា ។ អ្នកស្នើសុំផ្ទេរក្នុងខែមករា ត្រូវបានបើកប្រាក់

ឧបត្ថម្ភប្រចាំខែ នៅខែកក្កដា ឯអ្នកសុំផ្ទេរក្នុងខែកក្កដា ត្រូវបើកប្រាក់ឧបត្ថម្ភ នៅខែមករានៃឆ្នាំបន្ទាប់ នៅខេត្តក្រុងដែលខ្លួនស្នើសុំ ។

ការសម្រេចឱ្យផ្ទេរមុខសញ្ញា ពីខេត្តក្រុងមួយ ទៅខេត្តក្រុងមួយផ្សេងទៀត ត្រូវកំណត់ដោយប្រកាស របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ៥៨:** បែបបទនិងនីតិវិធីផ្ទេរមានកំណត់ដូចតទៅ:

គ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារនិងគ្រួសារត្រូវមានលិខិតស្នើសុំមកមន្ទីរ តាមរយៈការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុកខណ្ឌ តាមគំរូណែនាំ។ ផ្អែកតាមលិខិតស្នើសុំ របស់សាមីខ្លួន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើលិខិតស្នើសុំមកក្រសួង ដោយភ្ជាប់មកជាមួយនូវ:

- សំណុំលិខិត និងឯកសារពាក់ព័ន្ធទាំងអស់
- សៀវភៅបើកប្រាក់ឧបត្ថម្ភប្រចាំខែ

ថិរវេលានៃការបំពេញបែបបទផ្ទេរនេះ ត្រូវបានកំណត់ដូចតទៅ:

-ចាប់ពីពេលទទួលពាក្យស្នើសុំផ្ទេរ និងការបំពេញបែបបទ ពីថ្នាក់ស្រុកមកខេត្ត មានថិរវេលា៧ថ្ងៃ

-ពីថ្នាក់ខេត្តមកក្រសួង មានថិរវេលា១៥ថ្ងៃ

-ថ្នាក់ក្រសួងពិនិត្យ និងបំពេញបែបបទតាមនីតិវិធី និងសម្រេចចេញប្រកាសផ្ទេរ មានថិរវេលា២០ថ្ងៃ។

## ជំពូកទី ១២

## ការគ្រប់គ្រងសៀវភៅបើកប្រាក់ឧបត្ថម្ភនិងប័ណ្ណសំគាល់

## គ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ

**ប្រការ៥៩:** សៀវភៅបើកប្រាក់ឧបត្ថម្ភ និងប័ណ្ណសំគាល់គ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ត្រូវសរសេរបំពេញដោយ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង តាមប្រកាសទទួលស្គាល់មុខសញ្ញា និងសំណុំលិខិតឯកសាររបស់ក្រសួង។

**ប្រការ៦០:** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើលិខិតស្នើសុំហត្ថលេខានិងត្រា លើសៀវភៅបើកប្រាក់ឧបត្ថម្ភ និងប័ណ្ណសំគាល់មកក្រសួង ដោយភ្ជាប់មកជាមួយ បញ្ជីរាយនាមមុខសញ្ញានិងគ្រួសារ។ ចំពោះសៀវភៅបើកប្រាក់ឧបត្ថម្ភបានប្រើប្រាស់អស់ទំព័រ ត្រូវធ្វើលិខិតស្នើសុំប្តូរថ្មី ដោយភ្ជាប់មកជាមួយសៀវភៅចាស់មកផង។

**ប្រការ៦១:** សៀវភៅបើកប្រាក់ឧបត្ថម្ភ ត្រូវរក្សាទុកនៅកន្លែងបើកប្រាក់។ ពេលមុខសញ្ញាមកបើកប្រាក់ ត្រូវឱ្យមានផ្តិតមេដៃ ឬចុះហត្ថលេខាទទួលតាមខ្ទង់នៃខែឆ្នាំនីមួយៗ។

ប័ណ្ណសំគាល់មុខសញ្ញា និងគ្រួសារ ត្រូវប្រគល់ឱ្យសាមីជន ឬគ្រួសារប្រើប្រាស់ ពេលមកបើកប្រាក់ ឬក្នុងករណីដែលអាចប្រើបាន ។

**ប្រការ៦២:** សៀវភៅបើកប្រាក់ឧបត្ថម្ភ និងប័ណ្ណសំគាល់ ត្រូវគ្រប់គ្រង និងប្រើប្រាស់ឱ្យបានល្អ ពេលមានការខូចខាត ឬបាត់បង់ ត្រូវរាយការណ៍ ឱ្យបានទាន់ពេលវេលា និងច្បាស់លាស់ ដើម្បីក្រសួងពិនិត្យ និងផ្តល់លទ្ធភាពចេញ ឱ្យប្រើប្រាស់

ជាលើកទី២ ។

## ជំពូកទី ១៣
## ការគ្រប់គ្រងថវិកាសោធនអតីតយុទ្ធជន

**ប្រការ៦៣៖** ថវិកាសោធនអតីតយុទ្ធជន ត្រូវបានរៀបចំនិងដាក់ឱ្យប្រតិបត្តិ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិការដ្ឋ ស្របតាមស្ថានភាពជាក់ស្តែង និងធានាបាននូវដំណើរការ បើកជូនមុខសញ្ញាបានទៀងទាត់ ត្រឹមត្រូវ មានតម្លាភាព និងទាន់ពេលវេលា ។

**ប្រការ៦៤៖** រាល់គម្រោងថវិកាឆ្នាំ នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវរៀបចំ ដោយប្រមូលផ្តុំ សំរបសំរួលគំរោង ផែនការចំណាយ ក៏ដូចជាការកែតម្រូវថវិកា បញ្ចូលក្នុងផែនកាថវិការបស់ក្រសួង ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវមានផែនការកម្មវិធីចំណាយ ការកែតម្រូវថវិកា សំរាប់មុខសញ្ញា ចំណុះការគ្រប់គ្រងរបស់ខ្លួន បញ្ជូនមកនាយកដ្ឋានសោធនអតីតយុទ្ធជន ធ្វើការបូកសរុបអោយបានទៀងទាត់ តាមពេលវេលា កំណត់ ។

**ប្រការ៦៥៖** ផែនការ កម្មវិធី ចំណាយថវិកា សំរាប់មុខសញ្ញា ត្រូវបានគ្រោង និងរៀបចំដោយផ្អែកលើលទ្ធផល និងសកម្មភាពការងារដែលបានអនុវត្តកន្លងមក កំពុងអនុវត្ត និងតាមបណ្តាស្ថិតិតួលេខ ដែលក្រសួងស្ថាប័នានា បានផ្តល់ជូន និងការប៉ាន់ស្មាននូវលទ្ធភាពអនុវត្តទៅខាងមុខ ។ ការរៀបចំនេះ ត្រូវផ្អែកលើនីតិវិធីនិងបែបបទ នៃគោលរបបឧបត្ថម្ភ របស់មុខសញ្ញា តាមជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃវិធានហិរញ្ញវត្ថុ ស្របតាមច្បាប់ និងបទបញ្ជាថវិកា ដែលរដ្ឋបានកំណត់ ។

**ប្រការ៦៦៖** គម្រោងស្នើសុំចំណាយឥណទាន សោធនអតីតយុទ្ធជន ត្រូវអនុវត្តតាមផែនការ ដែលមានចែងក្នុងសៀវភៅថវិកា ស្របតាមច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិកា តាមនីតិវិធី និងបែបបទ នៃគោលរប់បឧបត្ថម្ភមុខសញ្ញា និងតាមមាត្រាកំណត់នៃប្រកាសទទួលស្គាល់មុខសញ្ញារបស់ក្រសួង ។

នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវលើកគំរោងស្នើសុំសេចក្តីសំរេចពីរដ្ឋមន្ត្រី ។

**ប្រការ៦៧៖** ឥណទានសោធនអតីតយុទ្ធជន ផ្តល់ការចំណាយសំរាប់តែលើការងារអតីតយុទ្ធជន និងគ្រួសារដែលមានប្រកាសទទួលស្គាល់និងកំណត់របបឧបត្ថម្ភត្រឹមត្រូវ តាមគោលការណ៍កំណត់ ។ ការបង្វែរឥណទាននេះ ចំណាយលើវិស័យ ផ្សេងៗបានលុះត្រាតែស្ថានភាពឥណទាននេះ លើសពីតម្រូវការចាំបាច់នៃមុខសញ្ញា និងដោយមានការយល់ព្រម ពីរដ្ឋមន្ត្រី ។

**ប្រការ៦៨៖** ប្រាក់ឧបត្ថម្ភប្រចាំខែ ត្រូវបើកឱ្យបានទៀងទាត់ តាមពេលវេលាកំណត់ ។ សាមីជនមកបើកប្រាក់ ត្រូវបង្ហាញលិខិតឬប័ណ្ណទទួលស្គាល់ ជូនភ្នាក់ងារបើកផ្តល់ ។ ក្នុងករណី ដែលក្រសួងផ្តល់សៀវភៅ និងប័ណ្ណទទួលស្គាល់ មិនទាន់ពេលវេលា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវចេញលិខិតបញ្ជាក់បណ្តោះអាសន្ន ឱ្យសាមីជនប្រើប្រាស់ដើម្បីបើកប្រាក់ ។ ត្រូវមានបញ្ជីរាយនាមអ្នកទទួលប្រាក់ និងសៀវភៅបើកប្រាក់ឧបត្ថម្ភ ដោយឱ្យសាមីជនផ្តិតមេដៃឬចុះហត្ថលេខាទទួលត្រឹមត្រូវ ។

**ប្រការ៦៩៖** ការបើកប្រាក់ឧបត្ថម្ភគ្រាដំបូង ឬប្រាក់រំលឹក ត្រូវបានធ្វើឡើងនៅពេល មានសាច់ប្រាក់គ្រប់គ្រាន់ ធានាបាននូវការបើកជូនមុខសញ្ញាតាមចំនួនកំណត់ ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវកំណត់ទីកន្លែង និង

ពេលវេលាឱ្យបានពិតប្រាកដ ច្បាស់លាស់ និងធ្វើសេចក្តីជូនដំណឹង ដល់មុខសញ្ញានិងក្រសួង ដើម្បីចាត់តាំងមន្ត្រីជំនាញចូលរួមពិនិត្យការបើកផ្តល់ ។

**ប្រការ៧០:** ការបើកប្រាក់ឧបត្ថម្ភជូនមុខសញ្ញា ត្រូវប្រគល់ជូនដល់ដៃត្រឹមត្រូវនិងគ្រប់ចំនួន។ សាមីជនមុខសញ្ញាទទួលប្រាក់ ត្រូវរាប់ឱ្យគ្រប់ចំនួនទើបទទួលយក។ មិនត្រូវឱ្យមានសកម្មភាព រៃអង្គាស បងិវភាគទាន ឬកាត់កង ប្រាក់ឧបត្ថម្ភរបស់មុខសញ្ញា។ ករណីសាមីជនមានធុរៈធ្ងន់ធ្ងរ មិនអាចមកបើកបាន ត្រូវមានលិខិតផ្ទេរសិទ្ធិ ឱ្យអ្នកមកបើកជំនួសដោយមានលិខិតបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់។ ភ្នាក់ងារបើកប្រាក់ ត្រូវដកលិខិតផ្ទេរសិទ្ធិ រក្សាទុកជាឯកសារ។

ការទិញ ការលក់របបឧបត្ថម្ភគោលនយោបាយ របស់អតីតយុទ្ធជនគ្រប់ប្រភេទ ត្រូវហាមឃាត់។

**ប្រការ៧១:** ប្រាក់ឧបត្ថម្ភគោលនយោបាយ សោធនអតីតយុទ្ធជន ត្រូវបើកជូនមុខសញ្ញា នៅតាមការិយាល័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុកខណ្ឌ។ ការិយាល័យនេះ ត្រូវធ្វើបញ្ជីរាយនាមមុខសញ្ញា ការដក និងការទូទាត់ប្រាក់ដោយមានការត្រួតពិនិត្យ និងផ្តល់មតិត្រឹមត្រូវ ពីការិយាល័យ អតីតយុទ្ធជនខេត្តក្រុង (ផ្នែកសោធនអតីតយុទ្ធជន) មុនដាក់ជូនថ្នាក់ដឹកនាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុងសំរេច ។

## ជំពូកទី១៤

## បទបញ្ញត្តិរួម

**ប្រការ៧២:** នាយកដ្ឋានសោធនអតីតយុទ្ធជន ពេលទទួលបានលិខិតឯកសារមុខសញ្ញា ពីក្រសួងស្ថាប័ន ឬខេត្តក្រុង ត្រូវពិនិត្យលិខិតឯកសារនោះ តាមបែបបទនីតិវិធីនិងគោលការណ៍បានកំណត់ ។ រាល់លិខិតឬសំណុំឯកសារពាក់ព័ន្ធ នឹងការងារអតីតយុទ្ធជន ផ្ញើមកនាយកដ្ឋានសោធនអតីតយុទ្ធជន ។ ចំពោះលិខិតឯកសារទាំងឡាយណា ខុសពីនីតិវិធី និងបែបបទគោលការណ៍កំណត់ នាយកដ្ឋានត្រូវធ្វើរបាយការណ៍ និងស្នើសុំយោបល់សំរេចពីរដ្ឋមន្ត្រី ។

**ប្រការ៧៣:** មុខសញ្ញានិងគ្រួសារ ដែលទទួលប្រាក់ឧបត្ថម្ភគោលនយោបាយបាន លុះត្រាតែមានសំណុំលិខិត និងឯកសារដូចតទៅ:

១-ប្រកាសទទួលស្គាល់ និងផ្តល់របបគោលនយោបាយមុខសញ្ញា ដែលបានចុះហត្ថលេខាជាផ្លូវការ ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬថ្នាក់ដឹកនាំក្រសួង ដែលបានទទួលសិទ្ធិប្រទាន ។

២-តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមមុខសញ្ញា ដែលត្រូវបានទទួលប្រាក់ឧបត្ថម្ភគោលនយោបាយ ត្រូវមានហត្ថលេខាពីប្រធានការិយាល័យជំនាញ ប្រធាននាយកដ្ឋាន សោធនអតីតយុទ្ធជន និងរដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំដែលបានទទួលសិទ្ធិប្រទាន ។

៣-សំណុំលិខិតឯកសារផ្ទាល់ខ្លួនរបស់មុខសញ្ញា ដែលចេញដោយក្រសួងឬស្ថាប័នដើម ។

**ប្រការ៧៤:** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ក្រោយពីបានទទួល ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយចំពោះមុខសញ្ញា តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមមុខសញ្ញា ដែលត្រូវទទួលប្រាក់ឧបត្ថម្ភ និងសំណុំលិខិតឯកសារមុខសញ្ញាពីក្រសួង ត្រូវធ្វើការត្រួតពិនិត្យ និងអនុវត្តតាមនីតិវិធី និងបែបបទបានកំណត់។

**ប្រការ៧៥:** ចំពោះមុខសញ្ញាថ្មី គ្រប់ប្រភេទ គ្រប់ថ្នាក់ ដែលក្រសួងចេញប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយ ការិយាល័យអតីតយុទ្ធជនខេត្តក្រុង (ផ្នែកសោធនអតីតយុទ្ធជន) ជាលេខាធិការឱ្យមន្ទីរ ត្រូវធ្វើការ

ស្រាវជ្រាវ ពិនិត្យអង្កេតវត្តមានមុខសញ្ញា និងគ្រួសារ តាមមូលដ្ឋានជាក់ស្តែង។ មុខសញ្ញានិងគ្រួសារ មានវត្តមានពិតប្រាកដ ត្រូវរៀបចំបែបបទលិខិតស្នាម និងលើកតម្រោងស្នើសុំថវិកា បើកជូនតាមរបបកំនត់។ ឯមុខសញ្ញាដែលពុំមានវត្តមាន ត្រូវធ្វើរបាយការណ៍ជូនក្រសួង។ មុខសញ្ញាអវត្តមាន ត្រូវព្យួរឈ្មោះក្នុងរយៈពេល៣ខែ ក្នុងរយៈពេលនេះ មន្ទីរត្រូវធ្វើសេចក្តីជូនដំណឹងតាមលំនៅស្ថាន និងអាជ្ញាធរដែនដី ចំនួន៣ដង ដើម្បីបានជ្រាប។ ផុតរយៈពេល៣ខែនេះ បើគ្មានដំណឹងឬគ្មានវត្តមាន ត្រូវលើកជាសំណើមកក្រសួង ដើម្បីលុបឈ្មោះចេញពីបញ្ជី បើកប្រាក់។

**ប្រការ៧៦:** សាមីមុខសញ្ញាឬគ្រួសារដែលបានលុបឈ្មោះ ហើយបានមកបង្ហាញខ្លួនវិញ ដោយមានលិខិតបញ្ជាក់ ពីអាជ្ញាធរឃុំសង្កាត់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវលើកជាសំណើមកក្រសួង ដើម្បីចេញប្រកាសទទួលស្គាល់និងផ្តល់របបឧបត្ថម្ភជូនវិញ ចាប់ពីថ្ងៃខែឆ្នាំ ដែលក្រសួងស្ថាប័នដើមបានកំណត់ ។

**ប្រការ៧៧:** រៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យអតីតយុទ្ធជនខេត្តក្រុង(ផ្នែកសោធនអតីតយុទ្ធជន) ត្រូវធ្វើរបាយការណ៍ បូកសរុបលទ្ធផលអនុវត្តការងារ ស្ថានភាពទូទៅរបស់មុខសញ្ញា ការបើកប្រាក់ឧបត្ថម្ភ និងស្ថានភាពថវិកា ជូននាយកដ្ឋានសោធនអតីតយុទ្ធជន ដើម្បីបូកសរុបលទ្ធផល ជូនក្រសួង។ ក្នុងករណីសំខាន់ចាំបាច់ ត្រូវឡើងមករាយការណ៍ ផ្ទាល់បន្ទាន់ ។

រៀងរាល់ ឆមាស និងឆ្នាំ នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវសហការជាមួយ នាយកដ្ឋាននានា និងអង្គភាពចំណុះក្រសួង រៀបចំកម្មវិធីប្រជុំដកពិសោធន៍ លើការអនុវត្តការងារចំណុចខ្លាំងខ្សោយ ដោយមានការចូលរួមពីថ្នាក់ដឹកនាំមន្ទីរ ការិយាល័យអតីតយុទ្ធជនខេត្តក្រុង ស្រុកខ័ណ្ឌ(ផ្នែកសោធនអតីតយុទ្ធជន) និងតំណាងក្រសួងពាក់ព័ន្ធ ចូលរួម។ ត្រូវមានការលើកសរសើរចំពោះ បុគ្គល អង្គភាព ដែលអនុវត្តមានស្នាដៃល្អ សំរេចបានតាមផែនការនិងគោលការណ៍កំណត់

**ប្រការ៧៨:** នាយកដ្ឋាន សោធនអតីតយុទ្ធជន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវមានកម្មវិធីផ្សព្វផ្សាយនូវគោលការណ៍ គោលនយោបាយ ច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីសំរេច សារាចរ សេចក្តីណែនាំពាក់ព័ន្ធជាមួយការអនុវត្ត របបឧបត្ថមគោលនយោបាយមុខសញ្ញា ឬការងារផ្សេងៗ សំដៅរក្សានូវនិរន្តរភាព ការងារសោធនអតីតយុទ្ធជននិងដើម្បីលើកកំពស់នូវគុណភាព សមត្ថភាពមន្ត្រីរាជការ ក្នុងការអនុវត្តការងារ។ ត្រូវធ្វើការអប់រំចំពោះមន្ត្រីសោធនអតីតយុទ្ធជនគ្រប់ថ្នាក់ ឱ្យមានសីលធម៌ អាកប្បកិរិយាល្អ និងមានស្មារតីស្មោះត្រង់ ក្នុងការបំពេញភារកិច្ចការបើកប្រាក់ឧបត្ថម្ភមុខសញ្ញា។ ត្រូវមានការលើកទឹកចិត្ត ដោយសរសើរ និងជូនរង្វាន់ ចំពោះមន្ត្រីរាជការសោធនអតីតយុទ្ធជនណា ដែលសកម្មក្នុងការអនុវត្តការងារបានល្អ ។ ទន្ទឹមនឹងនោះ ត្រូវមានវិធានការណ៍យ៉ាងម៉ឺងម៉ាត់ ជាក់ស្តែងស្របតាមច្បាប់ជាធរមាន ចំពោះមន្ត្រីអសកម្មទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ពីនីតិវិធី និងគោលការណ៍ ច្បាប់។

**ប្រការ៧៩:** នាយកដ្ឋាន សោធនអតីតយុទ្ធជន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវសហការ ឱ្យបានល្អក្នុងការពិនិត្យ និងដោះស្រាយគ្រប់បញ្ហា និងបាតុភាព ដែលកើតមានលើការងារអតីតយុទ្ធជន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងផ្ទាល់។ ត្រូវធ្វើរបាយការណ៍ ព្រមទាំងលើកវិធានការ អនុវត្តជាក់ស្តែង និងបំភ្លឺនូវគ្រប់បញ្ហានានា ជូនថ្នាក់ដឹកនាំក្រសួងផ្ទាល់ ឬក៏ក្រសួងស្ថាប័នរដ្ឋពាក់ពន្ធ័នានា ។

**ប្រការ៨០:** ករណីមានការទាមទារ តវ៉ា ពីបណ្តាមុខសញ្ញាតាមបែបបទជាលាយលក្ខអក្សរ ឬក៏តាមការជួបតវ៉ាដោយផ្ទាល់ មានលក្ខណៈជាពួកក្រុម ឬបុគ្គលផ្ទាល់នៅទីកន្លែងណា មន្ទីរ ឬការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត

ក្រុង ស្រុកខណ្ឌនោះ ត្រូវពិនិត្យដោះស្រាយនិងបំភ្លឺជូនតាមករណីនីមួយៗ ស្របតាមគោលការណ៍និងច្បាប់ជាធរមាន។ ត្រូវសហការណ៍ឱ្យបានល្អជិតស្និទ ជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងគ្រប់ស្ថាប័នអង្គភាពមានសមត្ថកិច្ច រាំងខ្ទប់ឱ្យបាននូវសកម្មភាពទាំងឡាយណា ដែលបង្កផលប៉ះពាល់ដល់គោលនយោបាយ និងកិត្យានុភាពនៃការដឹកនាំរបស់ រាជរដ្ឋាភិបាលកម្ពុជា។

## ជំពូកទី ១៥

## អវសានប្បញ្ញត្តិ

**ប្រការ៥១:** បទបញ្ញត្តិទាំងឡាយណា ផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥២:** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

គាត ឈន់

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ